**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**Kingdom of Cambodia**
**Nation Religion King**

**ក្រសួងរ៉ែ និងថាមពល**
**Ministry of Mines and Energy**
លេខៈ ០១៧.ទ៨.បល.សរណ

ថ្ងៃអង្គារ ៧កើត ខែអស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៨

# សេចក្តីជូនដំណឹង

## ស្តីពី

## កាលបរិច្ឆេទ និង មណ្ឌលប្រឡងចំពោះបេក្ខជនដែលបានដាក់ពាក្យសុំសិទ្ធិប្រឡង ប្រជែងជ្រើសរើសឱ្យចូលបម្រើការងារ ក្នុងក្របខណ្ឌក្រសួងរ៉ែ និង ថាមពល ឆ្នាំ២០១៨

គណៈកម្មការរៀបចំការប្រឡង សូមជូនដំណឹងដល់បេក្ខជន ដែលបានដាក់ពាក្យសុំសិទ្ធិប្រឡងប្រជែងជ្រើសរើសឱ្យចូលបម្រើការងារក្នុងក្របខណ្ឌក្រសួងរ៉ែ និង ថាមពលសម្រាប់ឆ្នាំ២០១៨ ឱ្យបានជ្រាបថា កាលបរិច្ឆេទ និង មណ្ឌលប្រឡង មានដូចខាងក្រោមៈ

**I. កាលបរិច្ឆេទប្រឡង**

***នៅថ្ងៃអាទិត្យ ទី២១ ខែតុលា ឆ្នាំ២០១៨*** តាមពេលវេលាដូចខាងក្រោមៈ

| | | | |
|---|---|---|---|
| **ពេលព្រឹកៈ** | ម៉ោង ៧:៣០ នាទី ដល់ម៉ោង ៩:០០ នាទី | វិញ្ញាសាវប្បធម៌ទូទៅ | មេគុណ ១ |
| | ម៉ោង ៩:៣០ នាទី ដល់ម៉ោង ១១:០០ នាទី | វិញ្ញាសាភាសាអង់គ្លេសទូទៅ | មេគុណ ១ |
| **ពេលរសៀលៈ** | ម៉ោង ១៤:០០ នាទី ដល់ម៉ោង ១៧:០០ នាទី | វិញ្ញាសាជំនាញបច្ចេកទេស | មេគុណ ២។ |

**II. មណ្ឌលប្រឡង**

***នៅសាលាបឋមសិក្សាព្រះនរោត្តម អគារ «ក»។***

អាស្រ័យហេតុនេះ សូមបេក្ខជនទាំងអស់ជ្រាបជាព័ត៌មាន និង សូមមកពិនិត្យឈ្មោះ លេខតុ និងលេខបន្ទប់ប្រឡង នៅទីស្តីការក្រសួងរ៉ែ និង ថាមពល ឬសាលាបឋមសិក្សាព្រះនរោត្តម ឬលើគេហទំព័ររបស់ក្រសួង នៅថ្ងៃសៅរ៍ ទី២០ ខែតុលា ឆ្នាំ២០១៨ វេលាម៉ោង ៩:០០ នាទី ព្រឹក។

*<u>បញ្ជាក់ៈ</u>* -ពេលចូលទៅកាន់បរិវេណមណ្ឌលប្រឡង បេក្ខជនត្រូវចូលតាមខ្លោងទ្វារសាលាពីខាងលិច ដោយត្រូវធ្វើដំណើរឆ្ពោះទៅកាន់អគារ«ក» តាមប្លង់បង្ហាញទីតាំងអគារ។
-បេក្ខជនត្រូវមកឱ្យដល់មណ្ឌលប្រឡង ឱ្យបានមុនម៉ោងកំណត់យ៉ាងតិច ៣០ នាទី។

**ជ.គណៈកម្មការរៀបចំការប្រឡង**
**ប្រធាន**

**ឌិត លីនដា**

លេខ ៧៩-៨៩ ផ្លូវប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥)២៣ ២១៩ ៥៧៤ ទូរសារ (៨៥៥)២៣ ២១៩ ៥៨៤
#79-89,Pasteur Street(51),Sangkat Phsar Thmey3,Khan Daun Penh,Phnom Penh Tel: (855) 23 219 574 Fax: (855) 23 219 584 www.mme.gov.kh info@mme.gov.kh